BMI0110

# សម្ភាសន៍ជាមួយឈ្មោះ តៅ តិ ភេទប្រុស អាយុ៧០ឆ្នាំ

## មុខងារជំនាន់ខ្មែរក្រហម“យោធា”

## រស់នៅភូមិស្វាយ ឃុំគំរូ ស្រុកថ្មពួក ខេត្តបន្ទាយមានជ័យ

ថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០១០

សម្ភាសន៍ដោយៈ សុខ វណ្ណៈ

០០:៥៩:៤៣

២៨ទំព័រ

សុខ វណ្ណៈ ជាដំបូងខ្ញុំសូមណែនាំខ្លួនថា ខ្ញុំឈ្មោះសុខ វណ្ណៈមកពីមជ្ឈមណ្ឌលឯកសារកម្ពុជា ។

តៅ តិៈ បាទ ។

សុខ វណ្ណៈ ខ្ញុំមកនេះចង់សរសេរសៀវភៅទុកឲ្យក្មេងជាជំនាន់ក្រោយបានដឹងពុថា ប្រទេសយើងជួបការលំបាកយ៉ាងណាខ្លះ?

តៅ តិៈ បាទ ។

សុខ វណ្ណៈ ហើយធ្លាប់ឆ្លងកាត់យ៉ាងម៉េចខ្លះ ចឹងបទសម្ភាសន៍ខ្ញុំជាមួយពូហ្នឹង តើពូអនុញ្ញាតឲ្យខ្ញុំយកទៅសរសេរជាសៀវភៅបានទេ?

តៅ តិៈ បាន ។

សុខ វណ្ណៈ ចឹងពូមិនថាអីទេ?

តៅ តិៈ បាទ!មិនថាអីទេ ។

សុខ វណ្ណៈ ចឹងជាដំបូងខ្ញុំចង់ស្គាល់ឈ្មោះពូ តើពូឈ្មោះអីដែរ?

តៅ តិៈ ឈ្មោះ តៅ តិ ។

សុខ វណ្ណៈ ចឹងពូអាយុប៉ុន្មានហើយ?

តៅ តិៈ អាយុ៧០ហើយ ។

សុខ វណ្ណៈ ចឹងប្រពន្ធពូឈ្មោះអីដែរ?

តៅ តិៈ ឈ្មោះរី លួត ។

សុខ វណ្ណៈ គាត់អាយុប៉ុន្មានដែរ?

តៅ តិៈ អាយុ៧១បងខ្ញុំ ។

សុខ វណ្ណៈ ចឹងមានកូនប៉ុន្មាននាក់?

តៅ តិៈ មានកូនពីនាក់ ។

សុខ វណ្ណៈ ស្រីទាំងអស់?

តៅ តិៈ ប្រុសមួយស្រីមួយ ។

សុខ វណ្ណៈ ចឹងកូនចៅរៀបការអស់ហើយ?

តៅ តិៈ រៀបអស់ហើយ ។

សុខ វណ្ណៈ ចឹងឪពុកពូឈ្មោះអីដែរ?

តៅ តិៈ ខ្ញុំស្គាល់តែឪពុកឈ្មោះ តៅ ជីតាមិនបានស្គាល់ទេ ។

សុខ វណ្ណៈ ចឹងម្ដាយឈ្មោះអិដែរ?

តៅ តិៈ ម្ដាយឈ្មោះ តុ មិនបានស្គាល់ត្រកូលទេ ។

សុខ វណ្ណៈ ចឹងឪពុកម្ដាយស្លាប់តាំងពីជំនាន់ណា?

តៅ តិៈ ជំនាន់ប៉ុល ពតហ្នឹង៦៨ ឪពុកម្ដាយដោយសារជំងឺ ។

សុខ វណ្ណៈ ចឹងបងប្អូនបង្កើតពូមានប៉ុន្មាននាក់?

តៅ តិៈ មាន១០នាក់ ។

សុខ វណ្ណៈ ចឹងសព្វថ្ងៃនៅសល់ប៉ុន្មាន?

តៅ តិៈ នៅសល់៦នាក់ ។

សុខ វណ្ណៈ មានស្លាប់ជំនាន់ប៉ុល ពតទេ?

តៅ តិៈ ស្លាប់មួយស្រី ។

សុខ វណ្ណៈ ឈ្មោះអី?

តៅ តិៈ ឈ្មោះ តៅ ឈឿប ។

សុខ វណ្ណៈ ចឹងអ្នកផ្សេងទៀតស្លាប់ក្រោយទេ?

តៅ តិៈ ហ្នឹងស្លាប់ដោយសារជំងឺ ។

សុខ វណ្ណៈ ចឹងពូមានស្រុកកំណើតនៅណា?

តៅ តិៈ នៅភូមិដូនស្វា ។

សុខ វណ្ណៈ ឃុំ?

តៅ តិៈ ឃុំចារឈូក ស្រុកពួក ខេត្តសៀមរាប ។

សុខ វណ្ណៈ ចឹងឥឡូវនៅភូមិអី?

តៅ តិៈ ភូមិស្វាយ ឃុំថ្មពួក ស្រុកថ្មពួក ខេត្តបន្ទាយមានជ័យ ។

សុខ វណ្ណៈ ចឹងកាលពីដើមពូរៀនបានដល់ថ្នាក់ណា?

គៅ តិៈ កាលពីដើមរៀនបានថ្នាក់ទី៧ "ចាស់" ។

សុខ វណ្ណៈ ចឹងទី៧ចាស់?

គៅ តិៈ បាទ!ទី៧ចាស់ប្រឡងធ្លាក់រត់ទៅបួសបណ្ដោយ ។

សុខ វណ្ណៈ រៀននៅសាលាណា?

គៅ តិៈ រៀននៅសាលាចារឈូក ។

សុខ វណ្ណៈ ចឹងបួសនៅវត្តណា?

គៅ តិៈ វត្តចារឈូកហ្នឹង ។

សុខ វណ្ណៈ ចឹងបួសបានប៉ុន្មានឆ្នាំ?

គៅ តិៈ បួសបាន៥ឆ្នាំ ។

សុខ វណ្ណៈ ចឹងសឹកនៅឆ្នាំណាមានចាំទេ?

គៅ តិៈ មិនបានចាំទេ យូរហើយ ។

សុខ វណ្ណៈ ចឹងសឹកហើយទៅធ្វើអីទៀតដែរ?

គៅ តិៈ សឹកហើយរៀបការប្រពន្ធ ។

សុខ វណ្ណៈ ចឹងពេលរៀបការហ្នឹងមានកើតរដ្ឋប្រហារហើយឬនៅ?

គៅ តិៈ ការមុនរដ្ឋប្រហារ ។

សុខ វណ្ណៈ ប្រហែលជាឆ្នាំណា?

គៅ តិៈ មិនបានចាំឆ្នាំទេ ។

សុខ វណ្ណៈ ចឹងមុនរដ្ឋប្រហាប៉ុន្មានឆ្នាំ?

គៅ តិៈ មុនរដ្ឋប្រហា៥ឆ្នាំ ។

សុខ វណ្ណៈ ចឹងរៀបការតាំងពីឆ្នាំ៦៥អីហ្នឹង?

គៅ តិៈ បាទ!ហ្នឹងហើយ រួចហើយបានកូន៥នាក់ ។

សុខ វណ្ណៈ ចឹងក្រោយមកទៀតពូធ្វើអីទៀត?

គៅ តិៈ ក្រោយមកដល់ឆ្នាំ៧០ខ្ញុំចូលបដិវត្តន៍ ។

សុខ វណ្ណៈ ចឹងកាលហ្នឹងពូយល់ឃើញយ៉ាងម៉េចបានចូលបដិវត្តន៍ហ្នឹង?

គៅ តិៈ កាលហ្នឹងបងប្អូនមកច្រើនណាស់ ស្បៀកខ្មៅពាក់ខ្មៅមកចលនាឲ្យបងប្អូនចូលធ្វើបដិវត្តន៍ ដើម្បីរំដោះជាតិ វ៉ៃចក្រព័ត្តអាមេរិក ចឹងខ្ញុំនឹកឃើញថា ស្រុកទេសយើងបាត់បង់ហើយ ក៏សម្រេចចិត្តចូលធ្វើ ។

សុខ វណ្ណៈ ចូលដំបូងនៅកន្លែងណា?

គៅ តិៈ ចូលដំបូងមកទីនេះតែម្តង មកបាត់ដំបងតែម្តង ។

សុខ វណ្ណៈ ចឹងចេញដំបូងមានទីតាំងនៅណា?

គៅ តិៈ កាលចេញមកដំបូងមកតាមជនបទស្រុកស្រែយើងណាស់ គេហៅថាតំបន់ខ្មាំង យើងគេហៅថាតំបន់រំដោះ កាលហ្នឹងវ៉ៃចុះឡើងទៅវាលំបាកណាស់ ខំទាំងយប់ទាំងថ្ងៃមិនបានដេក ពួនទេ ។

សុខ វណ្ណៈ ចឹងកាលឆ្នាំ៧០ ហ្នឹងមានលាយជាមួយកងទ័ពវៀតណាមទេ?

គៅ តិៈ កាលហ្នឹងវៀតណាមនៅដោយឡែក អង្គការយើងដោយឡែក វៀតណាមវាមកចេះទីសគ្នាវ៉ៃជាមួយវៀតណាមមួយសារទៀត ។

សុខ វណ្ណៈ តាមខ្ញុំដឹងនៅខាងបូព៌ាកាលឆ្នាំ៧១-៧២ហ្នឹងបានពឹងវៀតណាមឲ្យជួយ តែដល់ឆ្នាំ៧៣ ទើបដេញវៀតណាមឲ្យត្រឡប់ទៅវិញ?

គៅ តិៈ កាលហ្នឹងខាងសៀមរាបចូលចិត្តវៀតណាម តែខាងបាត់ដំបងអត់ទេ ។

សុខ វណ្ណៈ ចឹង?

គៅ តិៈ ឃើញយួនវ៉ៃតែម្តង កាលហ្នឹងយួនខាងហានណូយមិនមែនយួនខាងហ៊ុន សែនមិនមែនទេ កាលហ្នឹង ។

សុខ វណ្ណៈ តាមខ្ញុំដឹងកាលហ្នឹងខាងខ្មែររំដោះដោះហ្នឹងចូលជាមួយយួនហានណូយវ៉ៃជាមួយយួនថៅគី ខាងលនល់ នល់?

គៅ តិៈ បាទ!ខាងលន់ នល់ ។

សុខ វណ្ណៈ ចឹងខ្មែរនៅក្នុងប្រទេសនេះវាមានពីរក្រុម មានក្រុមខាងលន់ នល់និងក្រុមចលនារំដោះ?

គៅ តិៈ បាទ ។

សុខ វណ្ណៈ ខាងហ្នឹងចលនាក្នុងព្រៃក៏ពឹងយួននិងខាងលន់ នល់ក៏ពឹងយួនដែរ?

គៅ តិៈ បាទ!កាលឆ្នាំ៧០វ៉ៃជាមួយយួន ឆ្នាំ៧២វ៉ៃជាមួយយួន ចឹងដល់ឆ្នាំ៧៣ដេញយួនវិញ ។

សុខ វណ្ណៈ ចឹងកាលឆ្នាំ៧១-៧២យើងសហការជាមួយយួនដែរ?

គៅ តិៈ បាទ ។

សុខ វណ្ណៈ ចឹងដល់ឆ្នាំ៧៣ ខាងខ្មែរក្រហមមានកំលាំងគ្រប់គ្រាន់ហើយបានដេញយួនទៅវិញ?

គៅ តិៈ ដេញយួនទៅវិញ ។

សុខ វណ្ណៈ ចឹងសភាពការណ៍ហ្នឹងពូមានបានជួបទេ?

គៅ តិៈ មិនដែលបានជួបទេខ្ញុំ ។

សុខ វណ្ណៈ ចឹងនៅខាងខ្មែររំដោះរហូត?

គៅ តិៈ នៅខាងខ្មែររំដោះរហូតមិនដែលនៅជាមួយយួនទេ ។

សុខ វណ្ណៈ ចឹងកាលចលនាចូលឆ្នាំ៧០ហ្នឹង កាលហ្នឹងពីណាជាប្រធានហើយពីណាជាអ្នកនាំចូល?

គៅ តិៈ កាលហ្នឹងជាចលនាមួយជាស្នូររបស់បក្ស ខ្ញុំក៏នឹកឃើញទៅក៏ចូលជាមួយអង្គការហ្នឹង ។

សុខ វណ្ណៈ កាលហ្នឹងមានគ្នាច្រើនទេ?

គៅ តិៈ កាលហ្នឹងមានគ្នារាប់ពាន់នាក់ ចូលច្រើនណាស់ ចូលមួយថ្ងៃៗយកមិនអស់ទ័ព កាលហ្នឹងយន្តហោះទម្លាក់សាប់គោក្របី ខ្ញុំសាប់គោអស់មួយនឹម ។

សុខ វណ្ណៈ ចឹងនៅឆ្នាំណាដែលទម្លាក់ហ្នឹង?

គៅ តិៈ នៅឆ្នាំ៧០ហ្នឹងហើយ កាលហ្នឹងសាប់គោមួយនឹមខ្ញុំអត់គោធ្វើស្រែខ្ញុំចូលបដិវត្តន៍ទៅ ។

សុខ វណ្ណៈ បាទ ។

គៅ តិៈ ដើម្បីរំដោះជាតិទៅ ។

សុខ វណ្ណៈ ចឹងកាលទម្លាក់នៅកន្លែងណា?

គៅ តិៈ នៅភូមិដូនស្វា កាលនោះសាប់គោមួយនឹម បានខ្ញុំរកអីធ្វើស្រែមិនបានខ្ញុំចូលបដិវត្តន៍ ។

សុខ វណ្ណៈ ចឹងផ្ទះប្រជាជនយ៉ាងម៉េចដែរ?

គៅ តិៈ ផ្ទះប្រជាជនខ្ទិចខ្ទីអស់ច្រើនណាស់កាលហ្នឹង ។

សុខ វណ្ណៈ ចឹងមានប្រជាជនស្លាប់ទេ?

គៅ តិៈ មានប្រជាជនស្លាប់អស់៦នាក់ ។

សុខ វណ្ណៈ ចឹង៦នាក់ហ្នឹងនៅក្នុងភូមិហ្នឹង?

គៅ តិៈ បាទ! នៅក្នុងភូមិម្នាក់នោះម្តាយមួយកូនពីរសាប់ទាំងអស់ មួយទៀតនោះយាយចាស់ស្លាប់មួយទៀតក្មេងពីរនាក់ទៀតអស់៦ ខ្ញុំអស់គោមួយនឹម ។

សុខ វណ្ណៈ ចឹងកាលដែលពូចូលបដិវត្តន៍ហ្នឹង កាលហ្នឹងពូមានបានដឹងថាសម្តេចសីហនុផ្សាយពីប៉េកាំងមកថា កូនចៅចូលចលនាតស៊ូដើម្បីរំដោះជាតិ កាលហ្នឹងពូមានបានដឹងដែលឬមិនបានដឹងទេ?

តៅ តិៈ	កាលហ្នឹងបានដឹងច្បាស់ ថាកូនចៅអើយចូលបដិវត្តន៍ដើម្បីវ៉ៃចក្រពត្តិអាមេរិច ។

សុខ វណ្ណៈ	ចឹងសម្តេចផ្សាយនៅឆ្នាំណា?

តៅ តិៈ	គាត់ផ្សាយនៅឆ្នាំ៧១នេះឯង ជំនាន់រដ្ឋប្រហាហ្នឹង ។

សុខ វណ្ណៈ	ចឹងសម្តេចថាចូលព្រៃម៉ាគី?

តៅ តិៈ	បាទ!សម្តេចថាចូលព្រៃម៉ាគីកូន ដើមមីរំដោះប្រទេសរបស់យើង ពេលសម្តេចហៅហើយ ក៏ចូលទៅ ។

សុខ វណ្ណៈ	ចឹងនៅពេលពូចូលហើយតើពីឈរជើងនៅកន្លែងណា?

តៅ តិៈ	ខ្ញុំចូលមកខ្ញុំឈរជើងនៅក្រោមថ្នល់ជាតិលេខមួយព្រៃរនាមមានគ្នារាប់ពាន់នាក់ តែតាមកង១ណាស់ ។

សុខ វណ្ណៈ	បាទ ។

តៅ តិៈ	មួយកង១០០មួយកង១០០មានកងទូចកងធំណាស់ ។

សុខ វណ្ណៈ	បាទ ។

តៅ តិៈ	បាទ!រៀបតាមកងចឹងទៅល ។

សុខ វណ្ណៈ	កាលហ្នឹងប្រធានកងពលពូស្គាល់ទេ?

តៅ តិៈ	ប្រធានកងពលឈ្មោះបង នៅ តែស្លាប់ហើយគេយកវ៉ៃចោល ។

សុខ វណ្ណៈ	កាលហ្នឹងកងពលលេខប៉ុន្មាន?

តៅ តិៈ	កងពលលេខ៧ ខ្ញុំដូចជាភ្លេចហើយវាយូរណាស់ពេកហើយ លេខ៧ហ្នឹងហើយ ។

សុខ វណ្ណៈ	មានតាំងឆ្នាំអំឡុងឆ្នាំ៧០មកហ្នឹង?

តៅ តិៈ	តាំងពីឆ្នាំ៧១-៧២-៧៣ហ្នឹងមករហូត ។

សុខ វណ្ណៈ	ចឹងកងវរៈមាន១០០នាក់ចឹងទៅ?

តៅ តិៈ	បើកងធំមាន១០០តែវរៈមាន៣០០ ។

សុខ វណ្ណៈ	ចឹងវរៈតូចមាន១០០វរៈធំមាន៣០០ចឹង?

តៅ តិៈ	បាទ ។

សុខ វណ្ណៈ	ចឹងពេលដែលចូលទៅហើយមានសកម្មភាពវ៉ៃជាមួយទាហានលន់ នល់យ៉ាងម៉េចខ្លះទៅ?

តៅ តិៈ	មានច្រើនណាស់ គេចាប់បានយើង យើងចាប់បានគេវាលំបាកខ្លាំងណាស់ ។

សុខ វណ្ណៈ	ចឹងមានស្លាប់រស់ទាំងសងខាង?

តៅ តិៈ	បាទ ។

សុខ វណ្ណៈ ចឹងនៅពេលចាប់បានគ្នាទៅវិញទៅមកធ្វើម៉េចទៅ?

គៅ តិៈ មិនទុកទេ គេមិនទុលយើង យើងក៏មិនទុកគេ ។

សុខ វណ្ណៈ ចឹងមានន័យថាសម្លាប់ចោល?

គៅ តិៈ សម្លាប់ចោលតែម្តង ។

សុខ វណ្ណៈ ចឹងមិនថាខ្មែរគ្នាឯងទេ?

គៅ តិៈ មិនគិតចឹងទេ ចុះបើមាគ៌ាដឹកនាំទៅហើយ ។

សុខ វណ្ណៈ ចឹងដោយសារតែមាគ៌ាណែនាំ?

គៅ តិៈ បាទ! ដោយសារមាគ៌ាដឹកនាំ ។

សុខ វណ្ណៈ ចឹងកាលហ្នឹងគេអត់មានគិតពីច្បាប់សង្គ្រាមថា ចាប់បានឈ្លើយសឹកត្រូវទុកបានត្រឹមត្រូវទេ?

គៅ តិៈ បាទ! មិនមានទេ ចាប់បានមិនទុកទេ ។

សុខ វណ្ណៈ ចឹងកាលហ្នឹងអាវុធវ៉ៃជាមួយលន់ នល់បានមកពីខាងណាខ្លះ?

គៅ តិៈ បានមកពីចិន សម្បូរបែបណាស់ ។

សុខ វណ្ណៈ ចឹងកាលថ្ងៃទី១៧មេសាឆ្នាំ៧៥ពូមានបានវ៉ៃចូលដល់ភ្នំពេញទេ?

គៅ តិៈ ខ្ញុំមិនបានទៅទេ ខ្ញុំចូលខាងថ្មពួកនេះ កាលហ្នឹងឡើងតាមមុខសញ្ញា ។

សុខ វណ្ណៈ ចឹងពូវ៉ៃចូលត្រឹមខេត្តបាត់ដំបងទេ?

គៅ តិៈ បាទ ។

សុខ វណ្ណៈ មិនបានទៅភ្នំពេញទេ?

គៅ តិៈ បាត់ដំបងកងគេទៅ ។

សុខ វណ្ណៈ ចឹងពូមិនបានវ៉ៃចូលបាត់ដំបងទៀត?

គៅ តិៈ មុនហ្នឹងវ៉ៃចូលផ្តាច់ព្រាត់នៅឆ្នាំ៧៥នេះ គ្មានពីណាអាចជួយពីណាបានទេ ត្រូវទទួលខុសត្រូវបានសមរភូមិរៀងខ្លួន ចឹងចប់សង្គ្រាមបណ្តោយមក ខ្ញុំឡើងខាងថ្មពួកនេះឯងមានគ្នា ១០០នាក់ ។

សុខ វណ្ណៈ ចឹងនៅស្រុកពួកនេះ ពេលដែលខ្មែរក្រហមវ៉ៃបានចឹងមានជម្លៀសប្រជាជនចេញពីស្រុកពួកទេ?

គៅ តិៈ ភូមិនេះមិនមានជម្លៀសទេ ។

សុខ វណ្ណៈ ចឹងនៅពេលដែលចប់ហើយអង្គការចាត់តាំងពូទៅខាងណាទៀត?

តៅ គិៈ ខ្ញុំទៅនៅខាងភ្នំឆត្រ ការពារព្រំដែនថៃ ។

សុខ វណ្ណៈ ចឹងការពារនៅព្រំដែនថៃនៅកងវរៈប៉ុន្មាន?

តៅ គិៈ កងវរៈ៤១៥ ។

សុខ វណ្ណៈ ចឹងកងវរៈសេនាធំ ។

តៅ គិៈ កងវរៈសេនាធំ៤១៥ហ្នឹងជាកងពិសេស ។

សុខ វណ្ណៈ ចឹងកងពល?

តៅ គិៈ កងពលលេខ៧ហ្នឹង ដូចជាភ្លេចអស់ហើយ ។

សុខ វណ្ណៈ ចឹងកងពលក្រៅពីតានៅមានទីណាមកកាន់វិញ?

តៅ គិៈ កាលហ្នឹងនៅឆ្នាំ៧៦មានពួកនិរតីគេមក ។

សុខ វណ្ណៈ ចឹងខាងនិរតីចូលមកតាំងពីឆ្នាំ៧៦?

តៅ គិៈ បាទ! ។

សុខ វណ្ណៈ ចឹងកាលជំនាន់ហ្នឹងការពារនៅភ្នំឆត្រហ្នឹងមានព្រៃឈើច្រើនទេ?

តៅ គិៈ កាលហ្នឹងមានព្រៃឈើសម្បើមណាស់ សព្វថ្ងៃអស់ហើយគ្មានសល់ទេ ។

សុខ វណ្ណៈ ចឹងកាលជំនាន់ខ្មែរក្រហមការពារព្រៃឈើបានល្អ?

តៅ គិៈ បានល្អណាស់ គ្មានពីណាហ៊ានទេ សូម្បីតែថៃមិនហ៊ានទៀត ថៃមកកាប់មិនបានទេ ។

សុខ វណ្ណៈ ចឹងកាលជំនាន់ហ្នឹងនៅខេត្តបាត់ដំបងដែរ មិនទាន់កាត់ចូលខេត្តបន្ទាយមានជ័យទេ?

តៅ គិៈ មិនទាន់កាត់ចូលទេ ។

សុខ វណ្ណៈ ចឹងនៅបាត់ដំបងកាលហ្នឹងគេហៅថា តំបន់ប៉ុន្មាន?

តៅ គិៈ នៅសមរភូមិខ្ញុំគេហៅតំបន់៥ ។

សុខ វណ្ណៈ ចឹងគណៈតំបន់គណៈភូមិភាគពូមានស្គាល់ទេ?

តៅ គិៈ ស្គាល់ ។

សុខ វណ្ណៈ ឈ្មោះអី?

តៅ គិៈ រស់ ញឹម ជាគណៈភូមិភាគ ។

សុខ វណ្ណៈ ចឹងបន្ទាប់ពីរស់ ញឹមហើយពីណាគេទៀត?

តៅ គិៈ ធន ។

សុខ វណ្ណៈ ចឹងគណៈតំបន់?

តៅ គិៈ គណៈតំបន់ហ្នឹងឈ្មោះធនហ្នឹង ។

សុខ វណ្ណៈ ចឹងកាលសម័យតា រស់ ញឹម តា ធនអីហ្នឹង កាលហ្នឹងប្រជាជនរស់នៅយ៉ាងម៉េចដែរ?

តៅ តិៈ កាលហ្នឹងខ្ញុំទៅនៅព្រំដែនទៅ ប្រជាជនវេទនាណាស់ ខ្ញុំមិនសូវបានដឹងទេ។

សុខ វណ្ណៈ ចឹងមិនបានដឹងប្រជាជននៅខាងក្រោយ?

តៅ តិៈ បាទ!ហើយកាលវៃតប់កំន្ទេចខ្ញុំក៏មិនបានដឹង គេនៅខាងក្រោយមិនដឹងថាគេធ្វើអី។

សុខ វណ្ណៈ ចឹងកាលពូនៅជាទ័ពពីឆ្នាំ៧៥ដល់៧៩ហ្នឹង រយៈពេល៣ឆ្នាំជិត៤ឆ្នាំហ្នឹងពូនៅព្រំដែនរហូត?

តៅ តិៈ បាទ!នៅហ្នឹងរហូត។

សុខ វណ្ណៈ ចឹងពូមានដឹងថាបានវៃជាមួយថៃទេ?

តៅ តិៈ កាលហ្នឹងវៃជាមួយខ្មែរសេរី។

សុខ វណ្ណៈ ចឹងមានខ្មែរសេរីទៀត?

តៅ តិៈ មានច្រើនណាស់ ដូចជាមិនបានចប់សង្គ្រាមចឹង វៃរាល់ថ្ងៃជាមួយខ្មែរសេរីពួកប៉ារាហ្នឹងណាស់។

សុខ វណ្ណៈ ចឹងពួកប៉ារាមានយូរហើយចឹង?

តៅ តិៈ មានយូរហើយ។

សុខ វណ្ណៈ ជំនាន់ប៉ុល ពតហ្នឹងក៏មានដែរ?

តៅ តិៈ កាលទាហានលន់ នល់ រត់គេចមកនោះ។

សុខ វណ្ណៈ ចឹងទាហានលន់ នល់មាននៅក្នុងព្រៃទៀត?

តៅ តិៈ នៅក្នុងព្រៃជាមួយថៃ គេហៅថាខ្មែរសេរី។

សុខ វណ្ណៈ ចឹងពីឆ្នាំ៧៥ដល់៧៩វៃជាមួយទាហានខ្មែរសេរី?

តៅ តិៈ វៃជាមួយខ្មែរសេរី វៃមានស្លាប់មានរស់ណាស់ មិនមែនវៃលេងៗទេ ដូចមិនបានចប់សង្គ្រាមចឹងឯង។

សុខ វណ្ណៈ ចឹងខ្មែរសេរីហ្នឹងដល់វៃចាញ់ទៅយ៉ាងម៉េច?

តៅ តិៈ វៃចាញ់ចូលទៅដីថៃ បន្ទាយវានៅដីថៃ។

សុខ វណ្ណៈ ចឹងពួកហ្នឹងជាពួកលន់ នល់?

តៅ តិៈ ប្រហែលជាពួកលន់ នល់។

សុខ វណ្ណៈ ចឹងមានទាហានលន់ នល់នៅសេសសល់ចឹង?

តៅ តិៈ លន់ នល់នៅសេសសល់ដៃ

លរត់គេចទៅចាប់មិនបានអស់ ។

សុខ វណ្ណៈ ចឹងមានវៃឆក់គ្នាទៅវិញទៅ មករហូត?

តៅ តិៈ ហ្នឹងហើយដើរធ្វើការតាមផ្លូវ៤៥០ហ្នឹងផ្លូវមិនធំទេ វាលបចាំវៃយើង យើងលបបាន មុនវៃវាទៅគ្នាមានស្លាប់រស់ ។

សុខ វណ្ណៈ តែមិនច្រើនទេ មិនមានទ្រង់ទ្រាយធំទេ?

តៅ តិៈ មិនច្រើនទេ ដើរម្ដងមួយក្រុមអីទៅណាស់ តែវាច្រើនតែឆ្មក់យើង ។

សុខ វណ្ណៈ ចឹងកាលពូនៅយោធាព្រំដែនហូបចុកមានការលំបាកដែរ?

តៅ តិៈ មិនដែលលំបាកទេ មិនថាប្រជាជនអត់បាយយ៉ាងម៉េចផង ខ្ញុំមិនដែលបានដឹងចុះគេមិន ដែលឲ្យមកក្រោយនោះ ។

សុខ វណ្ណៈ ចឹងនៅក្នុងសម័យហ្នឹងពូមានដឹងថាយោធាត្រូវបានអង្គការចាប់ខ្លួនខ្លះទេ ខ្មែរក្រហមចាប់ ខ្មែរក្រហម?

តៅ តិៈ កាលឆ្នាំ៧៦ មានផែនការចាប់ហើយ ចាប់ខ្មែរក្រហមទាំងអស់ភូមិភាគពាយ័ព្យយើង ។

សុខ វណ្ណៈ ចឹងចាប់ទាំងអស់ឬយ៉ាងម៉េច?

តៅ តិៈ ចាប់ទាំងអស់ទាំងមេទាំងកូនដាក់គុកបាត់ដំបង គេហៅថាកកេកោះៗហ្នឹង ។

សុខ វណ្ណៈ ចឹងពូយ៉ាងម៉េចបានជាអង្គការមិនចាប់?

តៅ តិៈ ខ្ញុំរត់រួច ខ្ញុំរត់រួចម្នាក់ឯង បានស្រុះៗតាមភូមិរស់ដល់រាល់ថ្ងៃ កាលហ្នឹងគេគ្មានសល់ទេ ។

សុខ វណ្ណៈ ចឹងចាប់ទាំងកូនចៅ?

តៅ តិៈ ទេ កូននៅរស់ ។

សុខ វណ្ណៈ ទាំងកូនទាហាន?

តៅ តិៈ ទេ កូនទាហានយុវជនរស់មកវិញអស់ ។

សុខ វណ្ណៈ ចឹងយុវជនមិនអីទេ?

តៅ តិៈ មិនអីទេ យុវជន បើចាប់ពីមេក្រុមទៅ ប្រធានកងតូចកងធំអីចាប់ទាំងអស់ ។

សុខ វណ្ណៈ ចឹងលើកលែងតែកូនទាហានទេ?

តៅ តិៈ បាទ ។

សុខ វណ្ណៈ ចឹងយកទៅដាកលគុកបាត់ដំបងមានសម្លាប់ទេ?

តៅ តិៈ សម្លាប់ កាលហ្នឹងពួកនិរតីមកចាប់ ។

សុខ វណ្ណៈ ចឹងពូកាលហ្នឹងមានឋានៈអីដែរ?

តៅ តិៈ ឋានៈមេក្រុម មេក្រុមវែចោលដែលខ្ញុំរត់រួច កាលនោះនៅក្មេងដែលមិនចាស់អី ។

សុខ វណ្ណៈ ចឹងគេចខ្លួននៅក្នុងព្រៃតែម្ដង?

តៅ តិៈ នៅក្នុងព្រៃរហូតដល់យួនចូល ។

សុខ វណ្ណៈ ចឹងបានអីហូបនៅក្នុងព្រៃ?

តៅ តិៈ ហូបបាយជាមួយកងនេសាទខាងនោះឯង គេឃើញខ្ញុំស្លៀកពាក់ខោអាវខ្មៅគេស្មានថាខ្ញុំជាទ័ពណាស់ គេខ្លាចខ្ញុំដែរ ហូបបាយជាមួយគេខាងនេះមួយយប់ខាងនោះមួយយប់ដល់ ខ្ញុំទៅដល់ភូមិ

ភូមិទទួលខុសត្រូវហើយខ្ញុំនៅសឹកៗគេបានជាខ្ញុំបានប្រពន្ធនៅទីនោះ ។

សុខ វណ្ណៈ ចឹងកាលហ្នឹងដើរសុំបាយគេទៅ?

តៅ តិៈ បាទ ។

សុខ វណ្ណៈ ចឹងសុំតាមសហករណ៍?

តៅ តិៈ បាទ!តាមសហករណ៍តែនៅជាប់សហករណ៍តែមួយទេ មិនបានទៅណាទៅណីទេ គេហៅសហករណ៍ព្រីងដូគេឲ្យនៅរស់ទៅ ។

សុខ វណ្ណៈ តាមពិតបន្ទំខ្លួន?

តៅ តិៈ បន្ទំខ្លួន ខ្លាចគេណាស់កាលនោះ ។

សុខ វណ្ណៈ ចឹងកាលគេចាប់ហ្នឹងពួកខាងនិរតីមកពូមានស្គាល់ពួកនិរតីហ្នឹងទេ?

តៅ តិៈ មិនស្គាល់ទេ ។

សុខ វណ្ណៈ ចឹងពូមានដឹងថាចាប់មេខាងណាខ្លះទេ?

តៅ តិៈ ចាប់ច្រើនណាស់ កាលចាប់ផ្នែកទ័ព ភ្លេចអស់ហើយឈ្មោះ តា ធនគណៈតំបន់ចាប់មុនគេ ដូចជាភ្លេចឈ្មោះស់រលីង ។

សុខ វណ្ណៈ ចឹងមានដឹងថាគេចាប់តា ញឹមអីទេ?

តៅ តិៈ ដឹងថាគេចាប់អស់ហើយ អស់មេហើយ ។

សុខ វណ្ណៈ ចុះបន្ទាប់មកទៀតពូភ្លេចឈ្មោះហើយ?

តៅ តិៈ ភ្លេចឈ្មោះហើយ ក្រោយមមកចាប់ឈ្មោះអា លឿ មើលភ្លេចឈ្មោះគ្នាឯង ។

សុខ វណ្ណៈ ចឹងនៅហ្នឹងមានឈ្មោះតា ក្រកអីនោះ?

តៅ គិៈ	តា ក្រុក គាត់ជាគណៈឃុំនៅព្រះនេត្រព្រះ ហើយនៅនេះគេចាប់វ៉ៃចោលនោះចាប់គណៈស្រុកណាស់ ។

សុខ វណ្ណៈ	ចឹងគណៈស្រុកឈ្មោះអី?

តៅ គិៈ	គណៈស្រុកភ្លេចឈ្មោះ ខ្ញុំចេះតែភ្លេចឈ្មោះ បើមេភូមិឈ្មោះ អា សាំ ។

សុខ វណ្ណៈ	ចឹងមេភូមិចាប់ដែរ?

តៅ គិៈ	ចាប់ មេភូមិថ្មពួកនេះឈ្មោះសាំ គណៈស្រុកតា ហត ។

សុខ វណ្ណៈ	ចឹងកាលហ្នឹងមានការចាប់ខ្លាំងចឹងភ័យនាំគ្នារត់ទៅ ចឹងនៅតែមួយចំនួនទេ?

តៅ គិៈ	បាទ! នៅតែមួយចំនួនទេ ។

សុខ វណ្ណៈ	ចឹងពូកាលហ្នឹងជាយោធាខ្មែរក្រហមខាងណា?

តៅ គិៈ	យោធាខ្មែរក្រហមខាងពាយ័ព្យ ។

សុខ វណ្ណៈ	ខាងនិរតីស្អប់ភូមិភាគពាយ័ព្យ?

តៅ គិៈ	មិនយ៉ាងម៉េចថាឯងក្បត់ជាតិ ។

សុខ វណ្ណៈ	ចឹងពូយាមព្រំដែនរយៈពេលបីឆ្នាំហ្នឹង ពូមានដឹងថាប្រជាជនរត់ឆ្លងដែនច្រើនទេ?

តៅ គិៈ	មាន ។

សុខ វណ្ណៈ	ចឹងទៅពេលរត់ចឹងមានចាប់បានទេ?

តៅ គិៈ	ចាប់មិនដែលបានទេ មីនមិនដែលត្រូវទៀត ប្រជាជនស្មាយចេក ប្រជាជនយើងនេះរត់ទៅមិនដែលដឹងផង រត់ទៅដុតៗអស់ទៅណាស់ កាលហ្នឹងមនុស្សវ៉ៃចោលច្រើនវាប្រាលទៅអស់ ។

សុខ វណ្ណៈ	ចឹងនៅខាងយោធាហ្នឹងបើសិនជាចាប់បានបញ្ជូនមកក្រោយវិញឬចាប់បានវ៉ៃចោល?

តៅ គិៈ	បើចាប់បានបញ្ជូនមកខាងសហករណ៍គេវិញ មិនដែលធ្វើបាបទេ ។

សុខ វណ្ណៈ	ចឹងទាហានចាប់បានមិនធ្វើបាបទេ តែពូគិតមើលបញ្ជូនមកសហករណ៍វិញ?

តៅ គិៈ	មកសហករណ៍វិញមិនរស់ទេ ងាប់ហើយ ។

សុខ វណ្ណៈ	ចឹងមានប្រជាជនច្រើនទេ ដែលចាប់បញ្ជូនមកវិញ?

តៅ គិៈ	ខាងខ្ញុំមិនដែលចាប់បានទេ មានចាប់បានតែកងគេផ្សេង ។

សុខ វណ្ណៈ	ចឹងប្រហែលជាប្រជាជនគិតថា ខាងក្នុងលំបាកពេកប្រថុយរត់ទៅក្រែងបានរស់?

តៅ គិៈ	តែបើសិនជារត់ទៅហើយគេចពីជំរូងអីទៅ បើកងទ័ពឃើញបាញ់ទៅមានស្លាប់ខ្លះ ។

សុខ វណ្ណៈ	បាទ ។

តៅ តិៈ ស្លាប់ប្រជាជន ដែនការកាលហ្នឹងតឹងណាស់ បើឯងមិនធ្វើតាមគេឯងក៏មិនរស់ដែរ ។

សុខ វណ្ណៈ ចឹងបើមិនធ្វើតាមគេមិនរស់?

តៅ តិៈ មិនរស់ទេ ដាច់ខាតណាស់ប្រពន្ធកូនមិនឲ្យគិតទៀត ខ្ញុំមិនដែលបានឃើញមុខប្រពន្ធខ្ញុំផង កាលនោះតឹងណាស់ ។

សុខ វណ្ណៈ ចឹងប្រពន្ធកូនពូមិនដែលបានជួបគ្នាទេ?

តៅ តិៈ ជួបហើយជួបសព្វថ្ងៃ ។

សុខ វណ្ណៈ ចឹងប្រពន្ធកូនពូកាលបីឆ្នាំហ្នឹងមានដែលមកលេងផ្ទះទេ?

តៅ តិៈ ទេ មិនដែលបានមកទេ បើសុំគេមិនបានផង គេមិនឲ្យមកទេ ទ័ពមិនដូចសព្វថ្ងៃឯណា អា ចប់សង្គ្រាមហើយសុំមិនបានមកទៀត ។

សុខ វណ្ណៈ ចឹងកាលចប់សង្គ្រាមនៅឆ្នាំ១៩៧៩ពូនៅណា?

តៅ តិៈ ខ្ញុំនៅភូមិអន្លង់សាន ខ្ញុំបានប្រពន្ធសព្វថ្ងៃនេះហើយ គេការឲ្យពួកនិរតីការឲ្យ ។

សុខ វណ្ណៈ ចឹងឆ្នាំ៧៩មានចូលធ្វើទាហានខ្មែរក្រហមដដែល?

តៅ តិៈ បាទ ។

សុខ វណ្ណៈ ឆ្នាំ៧៩ហ្នឹង?

តៅ តិៈ ទេ កាលខ្ញុំរត់មកហើយខ្ញុំធ្វើប្រជាជនហើយ ។

សុខ វណ្ណៈ ចឹងឆ្នាំ៧៩រត់មកធ្វើប្រជាជនសិន?

តៅ តិៈ ទេ ឆ្នាំដែលគេរកចាប់ដាក់គុកបាត់ដំបង ខ្ញុំរត់រួចមកខ្ញុំធ្វើប្រជាជន ។

សុខ វណ្ណៈ បាទ ។

តៅ តិៈ ដល់ឆ្នាំ៧៩ខ្ញុំចូលធ្វើទ័ពទៀត វៃយួន គេហៅរកខ្ញុំទៀត ។

សុខ វណ្ណៈ ចឹងនៅឆ្នាំ១៩៧៩ហ្នឹង ធ្វើប្រជាជនមួយរយៈសិន?

តៅ តិៈ ធ្វើប្រជាជនបានមួយរយៈតូច នៅឆ្នាំ៧៩ហ្នឹងខ្ញុំចូលធ្វើខ្មែរក្រហមទៀត វៃយួននៅខាងទន្លេសាប ។

សុខ វណ្ណៈ ទន្លេសាបហ្នឹងនៅកន្លែងណា?

តៅ តិៈ នៅតាមព្រៃខាងកើតបាត់ដំបងណាស់ ខែវស្សាទឹកទៅខែប្រាំងក៏គោកទៅ ។

សុខ វណ្ណៈ ចឹងនៅឆ្នាំ១៩៧៩ហ្នឹង ពូយល់ឃើញយ៉ាងម៉េចបានចូលទៅធ្វើខ្មែរក្រហមទៀត ដូចពូបានដឹងហើយថា ខ្មែរក្រហមសម្លាប់ខ្មែរក្រហមហើយ ហេតុអីបានជាពូចូលបំរើទៀត?

តៅ គិៈ ចឹងបានថា ខ្ញុំទៅសៀមរាបប្អូនៗខ្ញុំថាបងឯងតស៊ូខុសហើយ បងឯងធ្វើខ្មែរក្រហមវេទនាណាស់ហើយ ម៉េចបានជាធ្វើខ្មែរក្រហមទៀត កាលហ្នឹងរត់ទៅតាមគេ គេនាំទៅក៏ទៅហ្នឹង គេ គេកុហក់ថាកងទ័ពខ្មែរក្រហមចាស់ៗតែឃ្លួនដឹងវា“អាកវះពោះច្រកស្មៅ” ចឹងភ័យ រត់ទៅទៀតទៅ បានជាប់ជាខ្មែរក្រហមទៀត បានថាខ្ញុំស៊យ ។

សុខ វណ្ណៈ ចឹងរត់តាមមិត្តភក្តិ?

តៅ គិៈ រត់តាមមិត្តភក្តិ គ្នាឯងមកហៅចេះតែទៅតាមគេទៅរហូតដល់ចប់ទៅ ។

សុខ វណ្ណៈ ចឹងកាលហ្នឹងមានទៅវៃខាងសំឡូត ម៉ាឡៃអីទេ?

តៅ គិៈ អត់ទេ ខាងនោះគេកងផ្សេង ។

សុខ វណ្ណៈ ចឹងខាងកងពលនៅខាងទន្លេសាបហ្នឹងពីណាគេ?

តៅ គិៈ បងសារឿន ។

សុខ វណ្ណៈ ឌុល សារឿន?

តៅ គិៈ មិនមែនទេ ។

សុខ វណ្ណៈ ចឹងបើឌុល សារឿនគាត់នៅខាងស្វាយចេក?

តៅ គិៈ បាទ! បងសារឿន តា វ៉ូយសព្វថ្ងៃនេះ ។

សុខ វណ្ណៈ តា វ៉ូយហ្នឹងគាត់នៅជាមួយឌុល សារឿន?

តៅ គិៈ ហ្នឹងហើយកាលនៅព្រៃ បង សារឿនគាត់ធំជាងណាស់ តា វ៉ូយគាត់អនុ ។

សុខ វណ្ណៈ ចឹងតា ឌុល សារឿនហ្នឹងទេ?

តៅ គិៈ បាទ!ហ្នឹងហើយតា សារឿនហ្នឹង ។

សុខ វណ្ណៈ ចឹងឌុល សារឿនពីស្វាយចេកដល់បឹងទន្លេសាបតែម្តង?

តៅ គិៈ បាទ ។

សុខ វណ្ណៈ ចឹងពីណាជាប្រធានធំ?

តៅ គិៈ បង សារឿនហ្នឹងហើយធំនោះ ចុះមកតា វ៉ូយ ។

សុខ វណ្ណៈ ចឹងបន្ទាប់ពីតា វ៉ូយមានពីណាទៀត?

តៅ គិៈ បន្ទាប់ពីតា វ៉ូយមកមានតា ម៉ៅ ។

សុខ វណ្ណៈ ចឹងបន្ទាប់ទៀត?

តៅ គិៈ បន្ទាប់មកហៀវ ហើយមានផ្នែកខុសៗគ្នាមានតា ស៊ូអីផង ។

សុខ វណ្ណៈ ចឹងព្រំ ស៊ូគាត់ធំជាងគា ម៉េអីទៀត?

គៅ តិៈ គាត់កងពលនោះ គាត់កងពលអូសទាញប្រជាជនខាងក្នុងចលនាខាងក្នុង ។

សុខ វណ្ណៈ ចឹងតា ម៉េមានឋានៈអីដែរ?

គៅ តិៈ ខាងទ័ព ។

សុខ វណ្ណៈ តែមិនមែនជាប្រធានកងពលទេ?

គៅ តិៈ ទេ អនុក្រោមៗមកទៀត តែសព្វថ្ងៃកងពលហើយ ។

សុខ វណ្ណៈ ចឹងឡុង ថែមមានស្គាល់ទេ?

គៅ តិៈ ស្គាល់ឡុង ថែមងាប់ហើយ ។

សុខ វណ្ណៈ គាត់កាន់ខាងអី?

គៅ តិៈ គាត់កាន់ខាងកងពលដែរ ច្រើនណាស់ ។

សុខ វណ្ណៈ ចឹងតា ម៉េនិងតា ហៀវហ្នឹងមានតួនាទីអីដែរ?

គៅ តិៈ ប្រធានវរៈសេនាធំ ខ្ញុំនិយាយតាមដែលខ្ញុំស្គាល់ទេ ។

សុខ វណ្ណៈ ចឹងមួយប៉ែកហ្នឹងខាងដុល សារឿនទេ?

គៅ តិៈ បាទ ។

សុខ វណ្ណៈ តែនៅខាងម៉ាឡៃ មានតា សុខ ភាព តា ហុង តាកន ពូមានស្គាល់ដែរ?

គៅ តិៈ មានស្គាល់ខ្លះៗដែរ ។

សុខ វណ្ណៈ ចឹងកាលពូចូលធ្វើទ័ពខ្មែរក្រហមហ្នឹងមានប្រាក់ខែទេ?

គៅ តិៈ គ្មានទេ ។

សុខ វណ្ណៈ ចឹងសម្ភារគ្រឿងសព្វាវុធមកពីខាងណា?

គៅ តិៈ គ្រឿងសព្វាវុធមកពីចិនទាំងអស់ កាំភ្លើងទំនើបណាស់កាលហ្នឹង កាលជិនាន់វៃជាមួយលន់ នល់ មិនសូវមានទេ ។

សុខ វណ្ណៈ បាទ ។

គៅ តិៈ នៅពេលវៃជាមួយយួននេះពេញហើយ ។

សុខ វណ្ណៈ ចឹងកាលហ្នឹងពូវៃខាងទន្លេសាបទេ មិនបានចល័តខាងម៉ាឡៃអីទេ?

គៅ តិៈ បាទៗ! ខាងទន្លេសាបនេះសហការជាមួយខាងម៉ាឡៃ ។

សុខ វណ្ណៈ ចឹងអ្នកដែលគ្រប់គ្រងធំ ដូចជានៅខាងម៉ាឡៃមានលោកតា អៀង សារីចឹងនៅខាងថ្មពួកនេះមានពីណាគ្រប់គ្រងដែរ?

តៅ តិៈ ថ្មពូកហ្នឹងបើក្តាប់រួមមានតា ហុងហ្នឹង ។

សុខ វណ្ណៈ ចឹងលើតា ហុងទៀត?

តៅ តិៈ លើតា ហុងទៀតមានពីណា មានតែអៀង សារីជីង ខៀវ សំផន ។

សុខ វណ្ណៈ ចឹងអត់ច្បាស់ដែរ?

តៅ តិៈ អត់ច្បាស់ដែលខ្ញុំ ។

សុខ វណ្ណៈ ចឹងតា នួន ជាមានដែលមកប្រជុំជាមួយទ័ពទេ?

តៅ តិៈ មិនដែលឃើញទេ បើសម្តេចឃើញ កាលហ្នឹងមកភូមិដូង ។

សុខ វណ្ណៈ ចឹងសម្តេចយាងមកភូមិដូងពូបានទៅដែរ?

តៅ តិៈ ទៅ ។

សុខ វណ្ណៈ ចឹងគេប្រមូលពីហ្នឹងទៅដែរ?

តៅ តិៈ ប្រមូលទៅការពារសម្តេច កាលនោះយួនប្រុងវ៉ៃហើយ គ្រាន់តែសម្តេចដកភ្នាមស្អែកឡើងយួនវ៉ៃបណ្តោយ វ៉ៃខ្ទិចកាលហ្នឹងមិនស្រួលទេ ។

សុខ វណ្ណៈ ចឹងនៅតំបន់ហ្នឹងកាលវ៉ៃជាមួយវៀតណាមចឹង ភូមិហ្នឹងមិនសូវជាមានព្រៃដូចនៅខាងម៉ាឡៃទេ?

តៅ តិៈ មិនសូវមានព្រៃទេ ម៉ាឡៃព្រៃណាស់ ។

សុខ វណ្ណៈ ចឹងពេលវ៉ៃគ្នាមិនឃើញមនុស្សរត់ទៅមកឃើញគ្នាហើយ?

តៅ តិៈ រត់ឃើញគ្នា ឃើញប្រជាជន ឃើញប្រជាជនណាស់ តែខ្ញុំមិនដែលប៉ះប្រជាជនទេ វ៉ៃតែ យួន យួនចាប់បានមិនដែលសម្លាប់ទេ យកទៅលើ ។

សុខ វណ្ណៈ ចឹងកាលហ្នឹងចាប់បានយួនមិនដែលសម្លាប់ទេ?

តៅ តិៈ អត់ទេ អង្គការមិនឲ្យសម្លាប់ទេយកទៅខាងលើ បើស្លាប់តាមសមរភូមិមិនដឹងជាធ្វើម៉េចទេ តែបើចាប់បានមិនដែលសម្លាប់ទេ ។

សុខ វណ្ណៈ មានដែលចាប់បានយួនច្រើនទេ?

តៅ តិៈ ចាប់បានច្រើនម្តងមាន៣០នាក់៥០នាក់ក៏មាន រត់ចូលមកមិនលំបាកវ៉ៃផង សុំចូលមកយកមួយរស់ យួនដែលចាប់បានមកយកទៅទុកកន្លែងក្បាលលាវហ្នឹង ដូចថាបាន១០០នាក់ចឹងទៅឲ្យថៃយកទៅបាត់ ថៃយកអង្ករមកឲ្យវិញ ។

សុខ វណ្ណៈ ចឹងយ៉ាងម៉េចបានដាបញ្ជូនឲ្យថៃវិញ?

តៅ តិៈ ថៃសុំ ។

សុខ វណ្ណៈ ចឹងយកទៅដូរអង្ករ?

គៅ តិៈ មិនដឹងដាដូរអីទេ ឃើញគេឲ្យអង្ករមកវិញ ។

សុខ វណ្ណៈ ចឹងមានការដោះដូរវិញ?

គៅ តិៈ បាទ ។

សុខ វណ្ណៈ ចឹងខាងថៃជាអ្នកទទួលឲ្យខាងវៀតណាមវិញក៏មិនដឹង?

គៅ តិៈ មិនដឹង ។

សុខ វណ្ណៈ ចឹងខាងខ្មែរក្រហមមានទំនាក់ទំនងល្អជាមួយថៃទេ?

គៅ តិៈ មិនអីទេថៃល្អណាស់ តែថៃធ្វើបាបប្រជាជនណាស់ ។

សុខ វណ្ណៈ ចឹងពូមានដឹងថាខាងថៃមានផលប្រយោជន៍អីជាមួយខាងខ្មែរក្រហមបានជាល្អជាមួយខ្មែរក្រហមចឹង?

គៅ តិៈ ថៃតាមខ្ញុំគិតទៅ កាលដែលខ្ញុំរ៉ៃជាមួយយួន មិនដឹងជាឆ្នាំប៉ុន្មានទេ ថៃជួយកាំភ្លើងធំចំនួន ៥ ដើមមករ៉ៃធ្លាក់មកដល់ស្វាយចេកហ្នឹង យួនដាក់ទៅវិញធ្លាក់ដល់ម្កាក់ទឹកខ្វាយនោះ ពួក ពួកខ្ញុំនៅកណ្ដាលចេះ ។

សុខ វណ្ណៈ ចឹងថៃបានជួយដែរ?

គៅ តិៈ ជួយ ។

សុខ វណ្ណៈ ចឹងពូមានដឹងថាថៃមានផលប្រយោជន៍អីដែរ?

គៅ តិៈ ខ្ញុំមិនសូវដឹងទេ ។

សុខ វណ្ណៈ ចឹងភូមិអ្នកស្រុកថ្មពួកហ្នឹងមានតាំងពីបុរាណមក?

គៅ តិៈ មានតាំងពីបុរាណទាំងអស់ ភូមិហ្នឹងមានយូរហើយ ។

សុខ វណ្ណៈ ចឹងប្រហែលជាប៉ុន្មានរយឆ្នាំមក?

គៅ តិៈ ខ្ញុំមិនដឹងដែរ ខ្ញុំនៅឆ្ងាយដែរ ខ្ញុំចូលមកនៅភូមិនេះឆ្នាំ៩៣ ។

សុខ វណ្ណៈ ចឹងនៅភូមិហ្នឹងកាលសម័យសង្គ្រាមពូមានដែលឃើញប្រជាជនស្លាប់ដោយសារសង្គ្រាម នៅពេលវៀតណាមវ៉ៃមក កាលហ្នឹងខ្មែរក្រហមនៅក្នុងព្រៃមែន?

គៅ តិៈ បាទ ។

សុខ វណ្ណៈ ចឹងនៅពេលដែលវៀតណាមវ៉ៃបុកមកខ្មែរក្រហមរត់ចូលព្រៃទៅ នៅពេលដែលវៀតណាមចូលដល់ក្នុងភូមិជួបប្រជាជនចឹង តើមានរឿងអីកើតឡើងពូមានដឹងទេ?

តៅ តិៈ ប្រជាជននៅតាមភូមិដូចជាភូមិកណ្ដុរភូមិត្រឡោក ភូមិកំពោរ ភូមិទ្រពង្យភូមិអន្លង់សាននេះ បើកាលណាយួនចង់មកវ៉ៃយើងចេះប្រជាជនប្រាប់មុន ។

សុខ វណ្ណៈ ចឹងប្រជាជនប្រាប់?

តៅ តិៈ បាទ!ប្រជាជនប្រាប់មុន ថាស្អែកយួនឡើងមកវ៉ៃហើយ យើងត្រៀមចាំស្រេចនៅនេះ ប្រជាជនចូលចិត្តយើងណាស់ បើចឹងម៉េចបានអត្តរស៊ី យើងឲ្យក្រណាត់ឲ្យសារ៉ុងឲ្យប៊ីចេង ទៅ ។

សុខ វណ្ណៈ ចឹងនៅក្នុងភូមិហ្នឹងពូមានដែលឃើញផ្ទះសំបែងត្រូវភ្លើងឆេះ ដោយសារគ្រាប់មានទេ?

តៅ តិៈ ទេ កាលឆ្នាំវ៉ៃជាមួយយួនមិនមានទេ បើកាលឆ្នាំវ៉ៃជាមួយលន់ នល់មាន ។

សុខ វណ្ណៈ ចឹងផ្ទះប្រជាជនមានត្រង់សេទេ?

តៅ តិៈ មានត្រង់សេគ្រប់ បើយើងចង់មកលេងដូចជាភូមិស្វាយហ្នឹងណាស់ ដូចនេះប្រជាជនរាយ ការណ៍ប្រាប់ ប្រជាជនប្រាប់ថាបងទៅមិនបានទេ យួននៅទីនោះឯង ។

សុខ វណ្ណៈ បាទ ។

តៅ តិៈ កាលណាយួនដកហើយ គាត់ប្រាប់ថាយួនដកហើយចូលមកលេងមក ។

សុខ វណ្ណៈ ចឹងមានប្រាប់ទៅវិញទៅមក?

តៅ តិៈ បាទ!ប្រជាជនចូលចិត្តយើងណាស់ ។

សុខ វណ្ណៈ ចឹងកាលដែលពូចូលជាខ្មែរក្រហមម្ដងទៀតតាំងពីឆ្នាំ៧៩មកហ្នឹងពូមានតួនាទីធំដែរ?

តៅ តិៈ ខ្ញុំគេឲ្យធ្វើចេះ ខ្ញុំគេឲ្យឃោសនាខាងប្រជាជន អប់រំប្រជាជនហៅមករៀនសូត្រ មិនដែល បានច្បាំងនិងគេទេ ។

សុខ វណ្ណៈ ចឹងជាទាហាននយោបាយ?

តៅ តិៈ បាទ!ជាទាហាននយោបាយ ឯងចាស់ចេះហើយណាស់ គេឲ្យឃោសនាប្រជាជនអប់រំប្រជាជន កុំឲ្យកាប់ព្រៃកុំឲ្យយួនប្រើខ្លាចត្រូវមិនត្រូវអី ប្រាប់សព្វគ្រប់ហ្នឹងឯងប្រាប់បងប្អូន ។

សុខ វណ្ណៈ ចឹងកាលពូនៅខាងទន្លេសាបអីហ្នឹងមានជំងឺគ្រុនចាញ់ទេ?

តៅ តិៈ នៅខាងនោះមិនមានទេ គ្រុនចាញ់ ។

សុខ វណ្ណៈ ចឹងមិនមានទេ?

តៅ គិៈ បាទ! បើខ្ញុំនៅខាងភ្នំដងរែក បងប្អូនដែលគេប្រើឲ្យកាប់ព្រៃហ្នឹងមានចាញ់ ហើយខ្ញុំចាប់បាន១០០នាក់យកទៅ បើសារ៉ុងម្នាក់មួយប៊ីចេងម្នាក់ពីរកញ្ចប់ ក្រណាត់មួយនាក់ពីរម៉ែត្រអ្នកទាំងហ្នឹងសុទ្ធតែរស់នៅខេត្តកំពង់ចាម ខ្ញុំជូនទៅវិញហើយប្រាប់បងប្អូនថាកុំមកកាប់ព្រៃថ្ងៃក្រោយប្រយ័ត្នងាប់ ត្រូវមីនត្រូវអី ។

សុខ វណ្ណៈ ចឹងនៅពេលខ្មែរក្រហមចាប់បានយួនចឹងយួនចាប់ខាងខ្មែរក្រហមយកទៅវិញយ៉ាងម៉េចដែរ មានដឹងសកម្មភាពហ្នឹងទេ?

តៅ គិៈ ចាប់យើងបានដូចជាមិនរស់ ។

សុខ វណ្ណៈ ចឹង?

តៅ គិៈ ពួកទាហានខ្មែរវ៉ៃចោល បើយើងចាប់បានខាងនោះមិនអីទេ ។

សុខ វណ្ណៈ ចឹងទាហានខ្មែរក្រហមត្រូវបានទាហានខ្មែរខាងក្នុងចាប់បានដែរ?

តៅ គិៈ បាទ! តែរេចឹនតែរត់ចូល ខ្មែរក្រហមរត់ចូលណាស់ បាត់ទាំងកាំភ្លើងក៏មិនថាអីទៅចុះ ។

សុខ វណ្ណៈ បាទ ។

តៅ គិៈ នៅពេលណាឡើងចុះពីភ្នំដងរែកទៅទន្លេសាបមួយយប់មួយថ្ងៃបានដល់ ហើយកងទ័ពបាត់មួយដងមាន៩នាក់១០ទៅសារភាព ។

សុខ វណ្ណៈ ចឹងបើសារភាពរស់?

តៅ គិៈ រស់ធ្វើម៉េចវា ហើយសារភាពហើយថ្ងៃក្រោយរកស៊ីត្រីនៅទន្លេសាបហ្នឹងទៀត មិនធ្វើអីទេ ល្អមើលដែលដូចជាថ្កុកល្មោនចឹង បើកាលសម័យឆ្នាំ៧០មិនបានទេ បើសារភាពហើយងាប់ហើយ សម័យសង្គ្រាមឆ្នាំ៧០ ។

សុខ វណ្ណៈ ចឹងដល់ក្រោយមកមិនអីទេ មានគោលការណ៍ថ្មី?

តៅ គិៈ មិនអីទេ មានគោលការណ៍ថ្មី ។

សុខ វណ្ណៈ ចឹងដល់ក្រោយមកពូធ្វើទាហានខ្មែរក្រហមដល់ឆ្នាំណាបានពូឈប់?

តៅ គិៈ ខ្ញុំកាលហ្នឹងពេលដែលយួនដកចេញពីប្រទេសកម្ពុជាអស់ទៅ គេហៅថាបង្រួបបង្រួមជាតិគេក៏ចូលមកខ្ញុំក៏ចូលមកទាំងអស់គ្នាទៅ ខ្ញុំគេដាក់បន្ទុកនៅខាងអន្លង់ត្រាចគេឲ្យធ្វើស្រែចឹងទៅ ធ្វើស្រែ១០០នាក់សម្រាប់កងទ័ព ។

សុខ វណ្ណៈ ចឹងនៅពេលដែលយួនដកថយហើយសង្គ្រាមនៅកើតខ្មែរនិងខ្មែរទៀត?

តៅ គិៈ នៅបន្តិចៗមិនសូវធំដុំទេ ។

សុខ វណ្ណៈ ចឹងកាលយួនដកនៅឆ្នាំ៨៧?

តៅ តិៈ បាទ!៨៧ វៃគ្នាមិនសូវខ្លាំងទេ បើយើងទៅគេគេចទៅ បើគេមកយើងគេចទៅ ។

សុខ វណ្ណៈ ចឹងនៅពេលខ្មែរវៃជាមួយខ្មែរហ្នឹងគេចិនមានផ្តល់ជំនួយឲ្យទៀតឬមួយឈប់ហើយ?

តៅ តិៈ ដូចជាមិនមានផ្តល់ទេ ។

សុខ វណ្ណៈ ចឹងឈប់ផ្តល់ហើយ?

តៅ តិៈ បាទ!ឈប់ហើយ ។

សុខ វណ្ណៈ ចឹងនៅឆ្នាំ៨៧ហ្នឹងពូមកធ្វើប្រជាជនហើយឬនៅ?

តៅ តិៈ មកធ្វើប្រជាជនហើយ ខ្ញុំឈប់មកធ្វើស្រែហើយដល់សព្វថ្ងៃនេះ ។

សុខ វណ្ណៈ ចឹងពូអត់មានចូលខាងប៉ារាអីទៀតទេ?

តៅ តិៈ អត់ទេ ប៉ារាខ្ញុំមិនដែលសោះ ប៉ារាចាប់ផ្តើមស្អប់តាំងពីធ្វើសង្គ្រាមជាមួយយួនមក ឃើញប៉ារាគឺវៃតែម្តង ។

សុខ វណ្ណៈ ចឹងឃើញប៉ារាខាងសម្តេចសីហនុអីអត់ពេញចិត្តដែរ?

តៅ តិៈ មិនពេញទេពួកខ្ញុំ ឃើញវៃតែម្តង ។

សុខ វណ្ណៈ ចឹងកាលហ្នឹងមានបីភាគីមែនទេ?

តៅ តិៈ បាទ ។

សុខ វណ្ណៈ មានខាងតា សឺន សាន និងខាងសម្តេចសីហនុ?

តៅ តិៈ បាទ ។

សុខ វណ្ណៈ ចឹងមានវៃជាមួយខ្មែរក្រហមដែរ?

តៅ តិៈ ស្អប់តែចេះ ស្អប់ធ្វើចោរដើរប្លន់អ្នកស្រុក ពួកខ្ញុំចាប់បានវៃចោលឲ្យរប៉េះហ្នឹង ធ្វើចោរប្លន់ប្រជាជន ។

សុខ វណ្ណៈ ចឹងមានប្លន់ចឹងខ្លាចគេចោទថាជាខ្មែរក្រហមប្លន់ដែរ ពេលចឹងឃើញប៉ារាធ្វើចឹងទឹង?

តៅ តិៈ ពេលគេប្លន់ចឹងទៅអ្នកស្រុកថាគេម៉ៅទាំងអស់ខំមួយពូជបណ្តោយ ។

សុខ វណ្ណៈ ចឹងនៅតំបន់ថ្មពួកចឹងប៉ារាមានតាំងពីឆ្នាំណាមក?

តៅ តិៈ ប៉ារាមានយូរហើយ ប៉ារាកើតចេញពីខ្មែរសេរីមក ក្រោយមកអ្នកស្រុកចេះតែចូលបន្តទៀតចេះតែច្រើនទៅ ។

សុខ វណ្ណៈ ចឹងខាងប៉ារាពូមានថាមេកើយខាងណាខាងណីទេ?

តៅ តិៈ មិនដឹងពីណាទេ ដឹងថាតា សឺន សានមេគេ ញ៉ឹក ប៊ុនឆៃទៅជួបខ្ញុំនៅខាងទន្លេសាបខ្ញុំមិនដែលធ្វើអី ។

សុខ វណ្ណៈ ចឹងមានជួបជាមួយញឹក ប៉ុនណែដែរ?

តៅ តិៈ ជួបគ្នាត្រូវគ្នាណាស់ ខ្ញុំដាក់ទ័ពដាក់ទូកដឹកម្ហូបមួយពាន់មិនតិចទេ តែទៅមិនយូរមួយខែពីរ ខែមកវិញអស់ បើយើងនៅចាំសមរភូមិ ខ្ញុំម៉ាធ្វើសង្រ្គាមតាំងពីឆ្នាំ៧០រហូតមកដល់យួន ទៀត ខ្ញុំមិនដែលមកក្រោយទេ ខ្ញុំនៅតែមុខរហូត ការពារខាងមុខ ចំពោះកងទ័ពដែល នៅខាងក្រោយគេថាកងស្រុកនោះ បើធ្វើបាបប្រជាជនយ៉ាងម៉េចខ្ញុំមិនដែលដឹងទេ ។

សុខ វណ្ណៈ បាទ ។

តៅ តិៈ កងទ័ពភាគមិនដែលដឹងសោះ កងទ័ពភាគមកលេងតាមភូមិគេមិនឲ្យមកទៀត គេខ្លាច ឃើញប្រជាជនស្គមៗវាពិបាក គេមកឲ្យមកទេទ័ព ។

សុខ វណ្ណៈ ចឹងពូគិតមើលថាថ្នាក់លើបានដឹងឬអត់រឿងរ៉ាវទាំងអស់ហ្នឹង គេមានគំនិតយ៉ាងម៉េច គេមានគំនិតហាមឃាត់មិនឲ្យខាងទ័ពដឹងពុ
ចឹងមានន័យថាគេចង់សម្លាប់ខ្មែរយើងឬថ្នាក់លើ បានដឹងឬមិនដឹងដូចជា ប៉ុល ពត អៀង សារី ខៀវ សំផនអីហ្នឹង គិតពូគិតមើលរឿង ដែលប្រជាជនអត់មានអាហារហើយយកប្រជាជនទៅសម្លាប់ហ្នឹង តើគាត់មិនបានដឹងមែន ឬគាត់ដឹងហើយធ្វើជាមិនដឹង?

តៅ តិៈ ខ្ញុំរកយល់មិនឃើញត្រង់ហ្នឹង ខ្ញុំគិតទៅមិនត្រូវ ។

សុខ វណ្ណៈ បាទ ។

តៅ តិៈ តែកន្លងមកដែលធ្វើជាកងទ័ពវៃលន់ នល់នោះណាស់ គឺខំណាស់កងទ័ពមានស្លាប់មានរស់ ទាហានលន់ នល់ មានស្លាប់មានរស់វេទនាសំបើមណាស់ ភ័យអរកណ្ដាលអធ្រាតុយប់ មិនបានដេកទេ ដើរតែវៃមួយយប់ៗ រំដោះជាតិបានទាំងស្រុកហើយបែរជាឲ្យប្រជាជន ហូបបបរ ម្យ៉ាងទៀតលំបាកមិនដែលបានជួបមុខប្រពន្ធកូនសោះ ។

សុខ វណ្ណៈ បាទ ។

តៅ តិៈ ចឹងបានជាខ្ញុំត្រូវបែកប្រពន្ធ កាលហ្នឹងគឺងណាស់ខុសសីលធម៌មិនបានទៀត ។

សុខ វណ្ណៈ បាទ ។

តៅ តិៈ មាននារីឃើញអន្ទុយតែពីរនាក់មិនបានទៀត ទាល់តែបីបួននាក់បាន ។

សុខ វណ្ណៈ ចឹងកាលហ្នឹងខ្មែរក្រហមមានគោលដៅស្អប់ទាហានលន់ នល់ មន្ត្រីរាជការ នាយទន់?

តៅ តិៈ បាទ ។

សុខ វណ្ណៈ ចឹងដល់ចាប់អ្នកទាំងអស់ហ្នឹងសម្លាប់អស់ទៅមិនដឹងជាយ៉ាងម៉េចបានមកចាប់ខ្មែរក្រហមគ្នា ឯងចឹងទៅវិញ?

គៅ គិៈ ចឹងបានជាខ្ញុំឆ្ងល់ត្រង់ហ្នឹងឯង បើដឹងថាចុះពីដើមខំធ្វើអី ។

សុខ វណ្ណៈ ចឹងយើងនិយាយតាមមើលឃើញទាំងអស់គ្នា យើងមិននិយាយកាន់ជើងខាងណាមួយទេ ព្រោះអ្នកនយោបាយគេមានគោរដៅរៀងៗខ្លួន ចឹងដូចថាកុំតែមានយួនរំដោះទេ តែរំដោះហ្នឹងមានអ្នកខ្លះគេមិននិយាយរំដោះទេ គេថាយួនឈ្លានខ្មែរ បើគិតតាមច្បាប់តាចឹង មែន តែកុំតែបានយួនឈ្លានពានចូលមកចឹងដេញខ្មែរក្រហមចេញអស់ចឹង តើពូគិតថាទាំងទ័ពខ្មែរក្រហមនិងប្រជាជនហ្នឹងមានស្លាប់បន្តទៀតឬយ៉ាងណា?

គៅ គិៈ ស្លាប់គ្មានសល់ទេ ចំពោះខ្ញុំក៏មិនសល់ទៀត តែបើយួនមិនចូលមកហ្នឹង ។

សុខ វណ្ណៈ បាទ ។

គៅ គិៈ បើកុំតែយួនចូលមកខ្ញុំក៏មិនសល់ទៀត ចឹងបានយួនចូលមកខ្ញុំអរណាស់មែន មិនមែននិយាយលេងទេ បើកុំបានយួនចូលឆ្នាំ៧៩ហ្នឹងខ្ញុំមិនរស់ទេ ។

សុខ វណ្ណៈ ចឹងស្រុកថ្មពួកមានតាំងពីណាពីណីមកមិនមានផ្លាស់ប្តូរទេ ចឹងមានដូរតែឃុំ ខេត្តទេ?

គៅ គិៈ បាទ ។

សុខ វណ្ណៈ ចឹងឆ្នាំណាដែលគេកាត់ខេត្តបាត់ដំបងមកបន្ទាយមានជ័យវិញ?

គៅ គិៈ ខ្ញុំមិនដឹងជាឆ្នាំណាទេ ។

សុខ វណ្ណៈ ចឹងកន្លែងពូរស់នៅនិងកន្លែងគុករស់នៅមានចម្ងាយឆ្ងាយពីគ្នាដែរ?

គៅ គិៈ ខ្ញុំមិនបានដឹងទេ ។

សុខ វណ្ណៈ ចឹងពូមានដឹងរឿងចោរប្លន់ខ្ចូចទេ?

គៅ គិៈ មិនបានដឹងទេ ។

សុខ វណ្ណៈ ចឹងនៅថ្មពួកយើងនេះមានចម្ងាយប៉ុន្មានពីព្រំដែនថៃដែរ?

គៅ គិៈ ប្រហែលជា១៥គីឡូ ។

សុខ វណ្ណៈ នៅជិតដែរ?

គៅ គិៈ នៅគៀកតើ មិនឆ្ងាយទេ បឹងត្រកួនដល់នេះជិះម៉ូតូ ។

សុខ វណ្ណៈ ចឹងចូលតាមបឹងត្រកួន?

តោ គិៈ បាទ ។

សុខ វណ្ណៈ ចឹងងាយរត់ទៅថៃដែរ?

តោ គិៈ ងាយដែរ ។

សុខ វណ្ណៈ តែពីបាករត់?

តោ គិៈ ពិបាករត់ តែកងទ័ពទៅថៃមិនបានទេ ថៃបាញ់ចោល ខ្ញុំតស៊ូអស់រយៈប៉ុន្មានឆ្នាំ តែខ្ញុំមិនបានធ្វើអីប្រជាជនទេ មិនបានប៉ះពាល់សោះ ។

សុខ វណ្ណៈ ចឹងឪពុកពូស្លាប់នៅឆ្នាំណា?

តោ គិៈ ស្លាប់យូរហើយ ខ្ញុំនៅនោះមិនដឹងថាគាត់ស្លាប់ផង ។

សុខ វណ្ណៈ ចឹងម្តាយ?

តោ គិៈ ម្តាយខ្ញុំដូចគ្នា ។

សុខ វណ្ណៈ ស្លាប់មុនជំនាន់ប៉ុល ពត?

តោ គិៈ បែបហ្នឹងហើយ ទេឪពុកខ្ញុំស្លាប់យូនចូលហើយ ប្អូនខ្ញុំប្រាប់ បើម៉ែស្លាប់មុនគាមដែលប្អូនប្រាប់ណាស់ ខ្ញុំទៅលេងស្រុកទើបតែមកតើ ប្អូនខ្ញុំមកយកទៅ ប្អូនមាន៥នាក់មានឡានទាំង៥នាក់មកយកទៅលេងស្រុក ខ្ញុំទៅលេងសប្បាយណាស់ ។

សុខ វណ្ណៈ ចឹងកាលដែលពូចូលព្រៃទៅមិនដែលបានដឹងសុខទុក្ខគ្រួសារយ៉ាងម៉េចទេ?

តោ គិៈ មិនបានដឹងទេ ។

សុខ វណ្ណៈ ចឹងមានបងប្អូនស្លាប់ជំនាន់ប៉ុល ពតតែម្នាក់ទេ?

តោ គិៈ មានតែម្នាក់ទេ ។

សុខ វណ្ណៈ ចឹងដោយសារពូមានរឿងរ៉ាវនិយាយបានច្រើនមកហើយ តើពូមានរឿងអីចង់និយាយបន្ថែមទៀតទេ?

តោ គិៈ ខ្ញុំចង់សួរចេះ ប្អូនៗចង់សួរអ្នកមានប្រវត្តិតស៊ូពីដើមហ្នឹងយកទៅធ្វើយ៉ាងម៉េចខ្លះ?

សុខ វណ្ណៈ ខ្ញុំមកនេះខ្ញុំចង់ដឹងប្រវត្តិរឿងរ៉ាវអីពូបងទាំងអស់ដែលធ្លាប់ឆ្លងកាត់ជាច្រើនជំនាន់មកហ្នឹង ៤ទៅ៥ជំនាន់មកហើយថាតើពាជួបរឿងរ៉ាវអីខ្លះ ចឹងយើងចង់បានរឿងរ៉ាវទាំងអស់ហ្នឹងយកទៅចងក្រងជាសៀវភៅទុកជាប្រវត្តិសាស្ត្រ ដូចថាជីវិតមនុស្សយើងមិនអាចរស់បានរហូតទេ ។

តោ គិៈ បាទ ។

សុខ វណ្ណៈ ខ្លះបានអាយុ១០០ខ្លះបាន៨០ទៅ៩០ស្លាប់បាត់ហើយ ។

តៅ តិៈ បាទ ។

សុខ វណ្ណៈ ចឹងនៅពេលដែលស្លាប់ទៅហ្នឹងពត៌មានដែលពូបានដឹងវាបាត់ទៅតាមហ្នឹងដែរ ដូច្នេះពូនិយាយប្រាប់នៅពេលនេះហើយ ដើម្បីចងក្រងជាសៀវភៅបានទុកឲ្យក្មេងជំនាន់ក្រោយមើលហើយវាជឿ បើយើងមិនបានកត់ត្រាទេ យើងនិយាយមាត់ទទេវាមិនអាចជឿយើងបានទេ បើយើងនិយាយគ្មានភស្តុតាងផងហ្នឹង ។

តៅ តិៈ ចឹងធម្មតាអ្នកតស៊ូដូច បង វ្ហយអីមានកត់ដែរ ។

សុខ វណ្ណៈ កត់ ខ្ញុំទៅសម្ភាសន៍តាំងពីគណៈស្រុកទាំងអស់ហ្នឹង ឲ្យតែគាត់ដឹងរឿងរ៉ាវច្រើន ចឹងយើងយកពត៌មានទាំងអស់ហ្នឹងជាពត៌មានសំខាន់ សម្រាប់ប្រទេសយើងទៅថ្ងៃក្រោយ ទោះបីជាពត៌មានអាក្រក់ក៏ដោយយើងយកទៅសិក្សាទៅ យើងហ្នឹងមានការជៀសវាង ថារបបនេះដឹកនាំចេះ របបនេះដឹកនាំចេះ ។

តៅ តិៈ បាទ ។

សុខ វណ្ណៈ ចឹងយើងមើលចំណុចដែលល្អចំណុចណាមិនល្អយើងត្រូវជៀសវាង ចឹងប្រជាជនយើងរស់រានមានជីវិតតទៅ ។

តៅ តិៈ បាទ ។

សុខ វណ្ណៈ ចឹងពូចំពោះរឿងតុលាការវិញ ពូធ្លាប់ឆ្លងកាត់របបហ្នឹងដែរ ថាតើពូយល់យ៉ាងម៉េចដែរចំពោះតុលាការហ្នឹង ចឹងពូគិតថាកាត់ទោសហ្នឹងវាមានប្រយោជន៍ បើមិនកាន់ទោសវាខាតប្រយោជន៍ឬអត់ប្រយោជន៍យ៉ាងម៉េច?

តៅ តិៈ ខ្ញុំថាកាត់ទោសពួកខាងលើហ្នឹងវាមានប្រយោជន៍ដល់សំខាន់ ទី១ចង់ឲ្យក្មេងជំនាន់ក្រោយវាដឹងពុថានេះ ដឹងនាំកាលហ្នឹង ។

សុខ វណ្ណៈ បាទ ។

តៅ តិៈ ចេះមួយៗមានប្រយោជន៍ បើយើងមិនធ្វើចឹងមិនមានប្រយោជន៍អីទេ ព្រោះប្រជាជនស្លាប់អស់រាប់លាននាក់ ។

សុខ វណ្ណៈ បាទ ។

តៅ តិៈ ដែលខ្ញុំនៅភូមិគេ ដែលខ្ញុំបានប្រពន្ធណាស់ ខ្ញុំមិនបានធ្វើការអីទេ ខ្ញុំធ្វើប្រជាជនហ្នឹងគេ ។

សុខ វណ្ណៈ បាទ ។

តៅ គិៈ តែខ្ញុំបានឃើញផ្ទាល់ភ្នែកខ្ញុំ កាលខាងនិរតីចុះមកក្នុងភូមិណាស់ កាលហ្នឹងវ៉ៃមេភូមិចាស់ចោល ។

សុខ វណ្ណៈ បាទ ។

តៅ គិៈ វ៉ៃគណៈឃុំចាស់ចោល ។

សុខ វណ្ណៈ បាទ ។

តៅ គិៈ ដាក់មេឃុំថ្មីគ្នាវាហ្នឹង ហើយប្រជាជនកាលនោះវាអន្តរាយណ៍អស់ហើយ មីនថាឯងដឹកដំឡូងមួយម៉ើមទេ វ៉ៃចោលខ្ទិច ។

សុខ វណ្ណៈ បាទ ។

តៅ គិៈ ខ្ញុំកាលហ្នឹងក្រវីតែក្បាលទេ ។

សុខ វណ្ណៈ ចឹងជិតនាន់បីឆ្នាំហ្នឹងជួបការលំបាកខ្លាំងណាស់?

តៅ គិៈ ពិបាកណាស់ ។

សុខ វណ្ណៈ ហើយក្រោយមកប្រទេសយើងជួបសង្គ្រាមបន្តទៀត វែងឆ្ងាយណាស់ ។

តៅ គិៈ បាទ ។

សុខ វណ្ណៈ ចឹងខ្ញុំអរគុណពូហើយដែលបានផ្តល់បទសម្ភាសន៍ ។

តៅ គិៈ បាទ ។

**ចប់**